**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ២៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០២ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៨/០១៣ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ៦ ទី ៨ ទី ១៤ និង ពិធីសារទី ៣ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា

ព្រះរាជាណាចក្រថៃ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រ េ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់ការបង្កើត និងកិច្ចដំណើរការរបស់ **គណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន** ហៅកាត់ថា **គជសដ** (National Cross-Border Transport Facilitation Committee-NCTFC) ដើម្បីសម្រួលអោយកាន់តែសាមញ្ញនូវនីតិវិធីគ្រប់គ្រង ត្រួតពិនិត្យ និងឃ្លាំមើលលើរាល់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែននូវទំនិញ មធ្យោបាយដឹកជញ្ជូន និងអ្នកដំណើរ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងការអនុវត្តល្អជាអន្តរជាតិ។

**គជសដ** មានលេខាធិការដ្ឋាននៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បម្រើការងាររបស់ខ្លួន។ ភារកិច្ចរបស់លេខាធិការដ្ឋាននេះ នឹងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំកញ្ចប់ថវិកាមួយដោយឡែក ក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង ដើម្បីធានានិរន្តរភាព នៃកិច្ចប្រតិបត្តិការ និងមុខងារនៃ **គជសដ** ។

## ជំពូកទី ២

## ផ្នែកទី ១

## សមាសភាព

**មាត្រា ២.-**

**គជសដ** មានសមាសភាពដូចខាងក្រោម ÷

១. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តំណាង ប្រធាន

| | | |
|---|---|---|
| ២. | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. | តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. | តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៥. | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៦. | តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៩. | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១០. | តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១១. | តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |

## ជំពូកទី ២

## តួនាទី និង ភារកិច្ច

**មាត្រា ៣.-**

**គជសដ** មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- សម្របសម្រួលកសាងផែនការសកម្មភាពជាយុទ្ធសាស្ត្រ ទាក់ទងនឹងការគ្រប់គ្រង និងការងារដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដើម្បីជម្រុញប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការកម្រិតខ្ពស់ក្នុងចំណោមបណ្តាក្រសួង និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ ការងារនេះ ត្រូវធានានូវតុល្យភាពរវាងការអនុវត្តបទប្បញ្ញត្តិច្បាប់ និងការសម្រួលពាណិជ្ជកម្ម ដើម្បីកាត់បន្ថយនូវពេលវេលា ការធ្វើសកម្មភាពត្រួតគ្នា និងការចំណាយលើបែបបទ ពាក់ព័ន្ធនឹងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។
- ស្រាវជ្រាវ ត្រួតពិនិត្យ និងវាយតម្លៃនូវនីតិវិធី និងបទប្បញ្ញត្តិច្បាប់ជាធរមាន ពាក់ព័ន្ធនឹងបែបបទនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន។ ក្នុងករណីចាំបាច់ ត្រូវរៀបចំនូវសេចក្តីព្រាងបទប្បញ្ញត្តិថ្មីមួយដែលមានប្រសិទ្ធភាពជាង ហើយដាក់ជូនរាជរដ្ឋាភិបាល ដើម្បីស្នើសុំការសម្រេច និងដាក់អោយអនុវត្តនូវបែបបទដឹកជញ្ជូនឆ្លងកាត់ព្រំដែនថ្មីនេះ តាមរយៈការធ្វើអោយស៊ីសង្វាក់គ្នា សាមញ្ញកម្ម និងទំនើបកម្មនូវបទប្បញ្ញត្តិទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន និងការអនុវត្តល្អជាអន្តរជាតិ ។

- សហការ សម្របសម្រួលការងារជាមួយបណ្ដាក្រសួង និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានាក្នុងករណីចាំបាច់ ដើម្បីធានានូវប្រសិទ្ធភាព និងអនុលោមភាពនៃការអនុវត្តនីតិវិធីដឹកជញ្ជូនឆ្លងកាត់ព្រំដែន ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។
- ផ្សព្វផ្សាយអោយបានទូលំទូលាយដល់បុគ្គលពាក់ព័ន្ធ ជាពិសេសសហគមន៍ធុរកិច្ចអោយមានការយល់ដឹងច្បាស់លាស់អំពីនីតិវិធី និងបែបបទនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។
- បង្កើតយន្តការតាមដានប្រសិទ្ធភាព និងអនុលោមភាពនៃការអនុវត្តនីតិវិធី និងបែបបទនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។
- ធ្វើរបាយការណ៍ជាប់ជាប្រចាំអំពីកិច្ចដំណើរការ និងសកម្មភាពអនុវត្តការងារ របស់ **គជសជ** ជូនរាជរដ្ឋាភិបាល ។

## ផ្នែកទី ៣
## សិទ្ធិ

**មាត្រា ៤.-**

**គជសជ** មានសិទ្ធិដូចតទៅ÷

- បង្កើតអនុគណៈកម្មាធិការជំនាញមួយចំនួន តាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ខ្លួន ។
- អញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ ឬអ្នកឯកទេសអោយចូលរួមប្រជុំ ពិគ្រោះពិភាក្សា ផ្តល់យោបល់ និងសិក្សាស្រាវជ្រាវ អោយបានទៀងទាត់លើរាល់បញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន ។
- ណែនាំដល់ក្រសួង- ស្ថាប័នពាក់ព័ន្ធ អោយកែសម្រួល ឬបំពេញបន្ថែមនូវបទប្បញ្ញត្តិ បច្ចេកទេសនានា សម្រាប់បម្រើដល់ការងារគ្រប់គ្រង និ ងត្រួតពិនិត្យការដឹកជញ្ជូនឆ្លងកាត់ព្រំដែនអោយកាន់តែសាមញ្ញ និងមានប្រសិទ្ធភាព ។

## ជំពូកទី ៣
## អវសានបញ្ញត្តិ

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះហត្ថលេខា

**គាត ឈន់**
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ដូចមាត្រា ៦
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ